ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣ ❀ ៩៩

ក្រសួងធនធានទឹក និងឧតុនិយម
លេខ ៧៩៥/៧៩ ធទឧ

# សេចក្តីជូនដំណឹង
## ស្តីពី ស្ថានភាពអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុរួចមក ឃើញថា បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងទទួលរងឥទ្ធិពលពីខ្យល់មូសុងឦសាន ដែលធ្វើឱ្យសីតុណ្ហភាពមានការថយចុះបន្តិច ។ ប៉ុន្តែ នៅក្នុងដំណាក់កាលនេះ ពោលគឺ ចាប់ពីថ្ងៃទី 24 ដល់ថ្ងៃទី 30 ខែវិច្ឆិកា ឆ្នាំ 2014 ព្រះរាជាណាចក្រកម្ពុជា ក៏នឹងទទួលរងឥទ្ធិពលបន្ថែមទៀតពីខ្យល់ដែលបក់មកពីសមុទ្រចិនខាងត្បូង ។ ការទទួលរងឥទ្ធិពលពីបាតុភូតធម្មជាតិទាំងពីរខាងលើនេះ នឹងធ្វើឱ្យស្ថានភាពអាកាស-ធាតុ នៅព្រះរាជាណាចក្រកម្ពុជា ( ពីថ្ងៃទី 24 ដល់ថ្ងៃទី 30 ខែវិច្ឆិកា ឆ្នាំ 2014 ) មានលក្ខណៈដូចខាងក្រោម :

- ផ្ទៃមេឃមានពពកច្រើន និងមានភ្លៀងធ្លាក់រាយប៉ាយពីតិច ទៅមធ្យម ក្នុងក្របខ័ណ្ឌទូទាំងប្រទេស
- សីតុណ្ហភាពអប្បបរមាមានពី 20-24 អង្សាសេ និងសីតុណ្ហភាពអតិបរមាមានពី 28-31 អង្សាសេ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ពិសេសបងប្អូនប្រជាកសិករ ដែលកំពុងប្រមូលផលស្រូវរដូវវស្សា និងកសិផលផ្សេងៗ មេត្តាជ្រាបជាព័ត៌មាន ។

*រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ2014*

រដ្ឋមន្ត្រី

លឹម_គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh